# ឥទ្ធិពលវិបត្តិហិរញ្ញវត្ថុពិភពលោកចំពោះមីក្រូហិរញ្ញវត្ថុកម្ពុជា

មីក្រូហិរញ្ញវត្ថុមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយបានផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋក្រីក្រទទួលបានប្រាក់ទុនយកទៅប្រកបអាជីវកម្មបានយ៉ាងមានប្រសិទ្ធិភាព។ ចរិតរបស់មីក្រូហិរញ្ញវត្ថុបានបោះទីតាំងប្រតិបត្តិការរបស់ខ្លួនដល់ទីជនបទដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋទទួលបានសេវាកម្មហិរញ្ញវត្ថុ។ មីក្រូហិរញ្ញវត្ថុមានលក្ខណៈខុសប្លែកពី ធនាគារពាណិជ្ជដែលជាទូទៅធនាគារពាណិជ្ជបានបោះទីតាំងប្រតិបត្តិការនៅតែតាមទីប្រជុំជនធំៗតែប៉ុណ្ណោះ ដែលមិនបានបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវាកម្មពីធនាគារឡើយ។ ដូច្នេះ យើងឃើញថា មីក្រូហិរញ្ញវត្ថុបានចូលខ្លួនមកបំពេញចន្លោះខ្វះខាតដែលមានពីមុនមក ដោយបោះទីតាំងខិតមកជិតប្រជាពលរដ្ឋ និងបើកទូលាយសេវាកម្មរបស់ខ្លួនដល់ ប្រជាពលរដ្ឋក្រីក្រទូទៅព្រមទាំងបញ្ជូនបុគ្គលិករបស់ខ្លួនទៅជួប និងណែនាំនៅតាមសហគមន៍អំពីសេវាកម្មមីក្រូហិរញ្ញវត្ថុ។

ការវិវឌ្ឍន៍របស់មីក្រូហិរញ្ញវត្ថុនៅកម្ពុជា គួរតែចែកចេញជាពីរដំណាក់កាលគឺមុន និងក្រោយឆ្នាំ ២០០០។ នៅមុនឆ្នាំ ២០០០ មីក្រូហិរញ្ញវត្ថុមិនសូវទទួលបានជោគជ័យទេដោយសារប្រជាពលរដ្ឋ មិនទាន់យល់ច្បាស់អំពីតួនាទីសំខាន់របស់មីក្រូហិរញ្ញវត្ថុ ក៏មិនបានផ្តល់កិច្ចសហការល្អដែរ ដូចនេះហើយធ្វើឱ្យសហគមន៍អន្តរជាតិដែលជាប្រភពផ្តល់ទុនមិនមានការទុកចិត្ត។ ប៉ុន្តែក្រោយឆ្នាំ ២០០០ នៅពេលយើងមានច្បាប់គ្រប់គ្រងមីក្រូហិរញ្ញវត្ថុ វិស័យនេះចាប់ផ្តើមទទួលបានជោគជ័យជាបន្តបន្ទាប់ រហូតដល់ខែ មករា ឆ្នាំ ២០០៦ យើងបានធ្វើសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុមួយ ដែលចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្រោមអធិបតីភាព របស់សម្តេចនាយករដ្ឋមន្ត្រី ដើម្បីកត់សម្គាល់ពីជោគជ័យរបស់វិស័យនេះ ដែលក្នុងនោះបានទទួលស្គាល់ថាមីក្រូហិរញ្ញវត្ថុ គឺជា **កូនសោរចាក់ទំលាយភាពក្រីក្រ**។ ជោគជ័យនេះគឺផ្អែកលើកត្តា ៤ យ៉ាងរួមមានៈ ទី១). ប្រជាពលរដ្ឋយល់ច្បាស់ថា មីក្រូហិរញ្ញវត្ថុជាកន្លែងដែលពួកគាត់អាចខ្ចីទុនដើម្បីប្រកបអាជីវកម្ម ហើយទុនដែលគាត់ទទួលបាន ត្រូវធ្វើការវិនិយោគឱ្យចំគោលដៅ និងដឹងច្បាស់ថាកម្ចីត្រូវសងវិញឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ទី២). ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុបានពង្រឹងសមត្ថភាពខ្លួនបានល្អដោយអនុវត្តតាមក្រមវិជ្ជាជីវៈ របស់ធនាគារ និងមីក្រូហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងក្រមសីលធម៌អាជីវកម្ម ព្រមទាំងផ្តល់ទុនចំគោលដៅ។ ក្នុងនោះដែរក៏បានបញ្ជាក់ពីការ គ្រប់គ្រងប្រាក់ទុនបានល្អតាមរយៈការសងត្រឡប់មកវិញបានគ្រប់គ្រាន់ និងទាន់ពេល។ ទី៣ៈ ភ្នាក់ងារហិរញ្ញវត្ថុអន្តរជាតិមានការទុកចិត្តជឿជាក់ និងទទួលស្គាល់ជោគជ័យធំធេងរបស់មីក្រូហិរញ្ញវត្ថុនៅកម្ពុជាបើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់។ លើសពីនេះគឺបានទទួលរង្វាន់ខ្នាតអន្តរជាតិពីរឆ្នាំជាប់គ្នា ២០០៥-០៦ ចំនួនសរុប ៧រង្វាន់ ក្នុងចំណោម ១៧ រង្វាន់ របស់ពិភពលោកដែលមានការចូលរួមប្រកួតពី ២៣១ គ្រឹះស្ថាន មកពី ៧៥ប្រទេស ក្រោមប្រធានបទតម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ពីអង្គការ CGAP (New York, USA)។ ទី៤ៈ រដ្ឋាភិបាលបានផ្តល់ការគាំទ្រតាមរយៈធនាគារជាតិនៃកម្ពុជា ដោយមានការរៀបចំនូវប្រព័ន្ធច្បាប់សមស្របដើម្បីគ្រប់គ្រង និងជ្រោមជ្រែងលើវិស័យនេះ ជាពិសេសគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរីដែលដាក់ឱ្យប្រើប្រាស់។

រហូតដល់បច្ចុប្បន្ននេះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៨ និងធនាគារពាណិជ្ជមួយ (អតីតមីក្រូហិរញ្ញវត្ថុ) បានពង្រីកសេវាកម្មរបស់ខ្លួនទៅកាន់ ២៤ ខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា និងមានសាខាសរុបចំនួន ៦២៣ សាខា។

យោងតាមរបាយការណ៏របស់ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានាដំណាច់ខែ ធ្នូ ឆ្នាំ ២០០៨ នេះ មានដូចតទៅ :

| Descriptions | 2006 | | | 2007 | | | 2008 | | |
|---|---|---|---|---|---|---|---|---|---|
| | Portfolio ($) | Clients | Change | Portfolio ($) | Clients | Change | Portfolio ($) | Clients | Change |
| 18 MFI | 88,693,911 | 449,826 | 77% | 154,732,293 | 604,660 | 74% | 276,288,068 | 820,513 | 79% |
| One Bank former MFI | | | | | | | | | |
| Micor loan | 85,861,022 | 151,578 | 38% | 116,512,236 | 172,719 | 36% | 161,423,018 | 194,613 | 39% |
| SME Loan | 74,861,031 | 8,352 | 84% | 198,798,065 | 12,773 | 166% | 301,930,666 | 19,724 | 52% |
| **18 MFI + Micro Loan** | **174,554,933** | **601,404** | **55%** | **271,244,529** | **777,379** | **55%** | **437,711,086** | **1,015,126** | **61%** |
| Total all | 249,415,964 | 609,756 | 63% | 470,042,594 | 790,152 | 88% | 739,641,752 | 1,034,850 | 57% |

**តើការរឹបអូសវត្ថុបញ្ចាំជាគោលដៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឬ?**

នៅពេលដែលវិបត្តិសេដ្ឋកិច្ចពិភពលោកជះឥទ្ធិពលដល់សេដ្ឋកិច្ចក្នុងស្រុក ការព្រួយបារម្ភមួយចំនួនបានលេចឡើងជុំវិញការសងបំណុលរបស់អតិថិជនមីក្រូហិរញ្ញវត្ថុ ស្តីពីការការរឹបអូសទ្រព្យសម្បត្តិប្រជាពលរដ្ឋដែលបានដាក់បញ្ចាំ។ ប៉ុន្តែ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបាននិយាយថា គោលបំណងមីក្រូហិរញ្ញវត្ថុគឺសំដៅលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានប្រសើរឡើង និងរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដូច្នេះការរឹបអូសទ្រព្យសម្បត្តិ ឬវត្ថុបញ្ចាំមិនមែនជាគោលដៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះឡើយ ហើយក៏មិនមែនឱ្យគេខ្ចីប្រាក់ដើម្បីចងរឹបអូសយកដីធ្លី ផ្ទះសម្បែង របស់ប្រជាពលរដ្ឋនោះទេ។

ការដាក់បញ្ចាំទ្រព្យសម្បត្តិ គឺមាននៅក្នុងកិច្ចព្រមព្រៀងរវាងម្ចាស់បំណុល និងអ្នកខ្ចីពិតមែន ប៉ុន្តែការអនុវត្តកន្លងមកគ្រឹះស្ថាននិមួយៗមិនទាន់មានការរឹបអូសទ្រព្យបញ្ចាំទាំងនេះទេ ប្រសិនបើមានករណីរឹបអូស គឺត្រូវធ្វើឡើងតាមផ្លូវច្បាប់ ពោលគឺតាមរយៈតុលាការ។ គោលការណ៍របស់មីក្រូហិរញ្ញវត្ថុ គឺបានកំណត់ច្បាស់ថាជោគជ័យរបស់អតិថិជន ជាជោគជ័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយគ្រឹះស្ថានមិនអាចមានជោគជ័យ លើការបរាជ័យរបស់អតិថិជនខ្លួនបានទេ បែបនេះមិនមែនជានិរន្តរភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ។

**ឆ្លើយតបចំពោះមតិលើកឡើងពីការសុំពន្យាពេលសងបំណុលៈ**

ការរីកចំរើនរបស់មីក្រូហិរញ្ញវត្ថុកន្លងមក ពិតប្រាកដគឺបានទទួលទុនពីប្រភពអន្តរជាតិដែលមានលក្ខណៈជាកម្មីពាណិជ្ជ-កម្ម ដែលគ្រឹះស្ថានត្រូវបង់សងជូនម្ចាស់បំណុលវិញ ដោយរួមមានទាំងប្រាក់ដើម ប្រាក់ការ និង កំរៃផ្សេងទៀត។ ចំពោះកិច្ចសន្យាខ្ចីនិមួយៗគឺបានកំណត់ជាក់លាក់ អំពីពេលវេលាត្រូវបង់សង និងចំនួនប្រាក់ត្រូវសងក្នុងវគ្គនិមួយៗ។ ដើម្បីកសាងជំនឿទុកចិត្តដល់ម្ចាស់បំណុលទាំងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិមួយៗបានខិតខំព្យាយាមបំពេញកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវដោយសងជូនម្ចាស់បំណុលគ្រប់ចំនួន និងគោរពបានតាមកាលបរិច្ឆេទដែលបានកំណត់។ ហេតុដូច្នេះហើយ ទើបវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានទទួលការទុកចិត្តយ៉ាងធំធេងពីសំណាក់អ្នកវិនិយោគទុនអន្តរជាតិជាច្រើនបានចូលមកវិយោគទុនរបស់គេក្នុងប្រទេសកម្ពុជាដែលបង្កលក្ខណៈងាយស្រួលក្នុងការអភិវឌ្ឍវិស័យនេះ។

ដើម្បីធានាបានការសងប្រាក់ដល់ម្ចាស់បំណុលវិញបានគ្រប់ចំនួន និងទាន់ពេលវេលានោះ គ្រឹះស្ថានក៏តំរូវឱ្យអតិថិជនរបស់ខ្លួនបង់សងត្រឡប់មកវិញបានគ្រប់ចំនួន និងទាន់ពេលវេលាដូចគ្នាដែរ។ ការខកខានការសងត្រឡប់របស់អតិថិជន នឹងបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការសងត្រឡប់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅម្ចាស់បំណុលវិញដែរ។ មានមតិមួយចំនួនបានលើកឡើងស្តីពីការសុំពន្យាពេលសងត្រឡប់របស់អតិថិជន ដោយអនុលោមតាមស្ថានភាពសេដ្ឋកិច្ចមិនល្អ។ សំណើរនេះស្តាប់ទៅងាយ ហើយសមគួរឱ្យទទួលយកបាន ក៏ប៉ុន្តែគឺជា**កត្តាគ្រោះថ្នាក់បំផុត**សំរាប់អាជីវកម្មមីក្រូហិរញ្ញវត្ថុ និងជាកត្តាភ័យខ្លាច បំផុតរបស់ប្រតិបត្តិករដែលយុទ្ធសាស្ត្រនេះគ្មានប្រវត្តិបានទទួលជោគជ័យទេនៅគ្រប់ប្រទេសនានាលើពិភពលោក ជាក់ស្តែងប្រទេសកម្ពុជាក៏ធ្លាប់បានឆ្លងកាត់បទពិសោធន៍នេះរួចមកហើយនាមុនឆ្នាំ ២០០០ (ចន្លោះឆ្នាំ ១៩៩៣-៩៩)។

បច្ចុប្បន្ននេះ យើងសង្កេតឃើញថា ការសងយឺតយ៉ាវមានកំរិតប្រមាណ ១% ប៉ុណ្ណោះ បើសិនជាយើងគិតថាអតិថិជនក្នុងចំណោម ១%នេះ ពិតជារងគ្រោះដល់វិបត្តិហិរញ្ញវត្ថុពិតប្រាកដមែន ហើយស្វែងរកការសុំពន្យាពេលសង យើងខ្ញុំជឿជាក់ថាអតិថិជន ៩៩%ទៀតដែលកំពុងមានលទ្ធភាពសងទាន់ពេលបច្ចុប្បន្ននេះ នឹងក្លាយជាអ្នករងគ្រោះដោយវិបត្តិហិរញ្ញវត្ថុដែរ ហើយទីបញ្ចប់អតិថិជន ១០០% នឹងគ្មានលទ្ធភាព សងទាំងអស់គ្នា បន្ទាប់មកនឹងស្វែងរកការពន្យាពេលសង ហើយទីបញ្ចប់នឹងធ្វើការស្នើសុំលើកលែងបំណុល។ នៅពេលដែលគ្រឹះស្ថានមិនអាចប្រមូលការសងត្រឡប់វិញបានធ្វើឱ្យគេមិនអាចមានលទ្ធភាពសងត្រឡប់ទៅម្ចាស់បំណុលវិញបានដែរ ដូច្នេះធ្វើឱ្យបាត់បង់ជំនឿទុកចិត្តរបស់អ្នកវិនិយោគអន្តរជាតិមកលើមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ហើយពួកគេនឹងបញ្ឈប់ការផ្តល់ទុន។ ពេលជួបនឹងវិបត្តិគ្មានប្រភពទុននោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ នឹងបញ្ឈប់ប្រតិបត្តិការហើយ

បញ្ឈប់អាជីវកម្មរបស់ខ្លួន។ ដូច្នេះនៅកម្ពុជានឹងគ្មានមីក្រូហិរញ្ញវត្ថុទៀតទេ ហើយអតិថិជនជាង ១ លាននាក់ដែលកំពុងតែប្រើប្រាស់សេវាកម្មបច្ចុប្បន្ន និងសមាជិកគ្រួសារគេប្រមាណ ៤លាននាក់ថែមទៀត (តាមសំរង់ស្ថិតិរបស់ក្រសួងមហាផ្ទៃនៅខែ មីនា ឆ្នាំ ២០០៨ មួយគ្រួសារមានសមាជិក ៤.៧ នាក់) និងលែងទទួលបានផលប្រយោជន៍ពីវិស័យនេះទៀតហើយ ដូចនេះ អ្នកដែលទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុតគឺប្រជាពលរដ្ឋខ្មែរក្រីក្រនោះឯង ហេតុនេះហើយការពន្យាពេលសងគឺជាកត្តាគ្រោះថ្នាក់បំផុត។ ដូច្នេះ យើងត្រូវមើលព្រៃទាំង មូល មិនមែនមើលដើមឈើមួយដើមៗនោះទេ (ជាប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី)។

**តើអតិថិជនដែលមានការលំបាកក្នុងការសងចំនួន ១% បច្ចុប្បន្ននេះពិតជារងគ្រោះដោយវិបត្តិហិរញ្ញវត្ថុពិតមែនឬ?**

នៅក្នុងប្រវត្តិសាស្ត្រមីក្រូហិរញ្ញវត្ថុការសងយឺតយ៉ាវមានចន្លោះពី ១% - ៥% កើតមានមុនឆ្នាំ ២០០៨ ពោលគឺកើតមានមុនពេលមានវិបត្តិហិរញ្ញវត្ថុ គឺជារឿងធម្មតានៅក្នុងអាជីវកម្ម។ ជាបទពិសោធន៍របស់ប្រតិបត្តិករគឺបានរកឃើញថាការខកខាននៃការសងបំណុលមួយចំណែកធំជាកំហុសរបស់អតិថិជន ដែលមិនបានគ្រប់គ្រងប្រាក់ទុនរបស់ខ្លួនឱ្យបានល្អ វិនិយោគមិនចំទិសដៅដែលបានសន្យា លើសពីនេះទៅទៀតអតិថិជនមួយចំនួនបានលាក់បាំងការពិតជាមួយមន្ត្រីមីក្រូហិរញ្ញវត្ថុអំពីបំណុលរបស់ខ្លួន ដើម្បីទទួលទុនពីគ្រឹះស្ថានផ្សេងៗច្រើនទៀត ធ្វើឱ្យពួកគេជំពាក់បំណុលច្រើនហួសលទ្ធភាពដែលពួកគេអាចសងបាន នាំឱ្យមានការបរាជ័យកើតមានឡើង ម្យ៉ាងទៀត អតិថិជនគោលដៅរបស់មីក្រូហិរញ្ញវត្ថុ គឺសំដៅចំពោះអតិថិជនខ្នាតតូច ដូចជា វិស័យកសិកម្ម ឬអាជីវកម្មតូចតាច ដែលបំរើសេចក្តីត្រូវការក្នុងស្រុក គឺមិនពាក់ព័ន្ធផ្ទាល់ទៅនឹងវិបត្តិហិរញ្ញវត្ថុពិភពលោកនោះឡើយ។

ការកសាងសហគ្រិនភាព គឺជាដំណោះស្រាយល្អបំផុតដើម្បីរំដោះខ្លួនឱ្យផុតពីភាពក្រីក្របាន។ ក្នុងនាមជាសហគ្រិន ជាម្ចាស់ពិតប្រាកដ គឺត្រូវទទួលខុសត្រូវលើអាជីវកម្មរបស់ខ្លួន រួមទាំងការចំណាយ ចំណូល និងប្រាក់បំណុល។ ការប៉ុនប៉ងគេចវេសណាមួយពីភាពទទួលខុសត្រូវរបស់ខ្លួននោះ គឺជាដំណើរទៅរកការបរាជ័យរបស់សហគ្រិន ដែលបង្កឱ្យគ្មានការជឿជាក់ទុកចិត្តពីសំណាក់ដៃគូ អាជីវកម្ម ពាណិជ្ជកម្មផ្សេងទៀតឡើយ ដូច្នេះគេនឹងបាត់បង់ឱកាសអាជីវកម្មរបស់គេ ដែលកត្តានេះមិនអាចឱ្យគេមិនអាចចាកចេញពីភាពក្រីក្របាននោះឡើយ។ ផ្ទុយទៅវិញ ដើម្បីធានាបាននូវជោគជ័យអតិថិជនម្នាក់ៗ គួរតប្បីខិតខំប្រឹងប្រែងគ្រប់គ្រង និងទទួលខុសត្រូវអាជីវកម្មរបស់ខ្លួនធានាបាននូវតម្លាភាព រួមទាំងការទទួលខុសត្រូវលើបំណុល គឺសងត្រឡប់មកវិញឱ្យបានគ្រប់ចំនួន និងទាន់ពេល។

ដូចគ្នានេះដែរ ដើម្បីកសាងទំនុកចិត្តនៅក្នុងទីផ្សារហិរញ្ញវត្ថុ និងធានាបាននិរន្តរភាពវិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ប្រតិបត្តិករនិមួយៗ បានប្តេជ្ញាចិត្តខិតខំប្រឹងប្រែងគោរពទៅតាមកិច្ចសន្យារបស់ខ្លួនដែលបានធ្វើជាមួយម្ចាស់ឥណទាន ពោលគឺត្រូវសងវិញឱ្យបានទាន់ពេល និងគ្រប់ចំនួនដែលបានសន្យា។ ដើម្បីសំរេចបានតាមការប្តេជ្ញានេះ ប្រតិបត្តិករបានផ្តោតការយកចិត្តទុកដាក់លើគុណភាពឥណទានរបស់ខ្លួន។ យុទ្ធសាស្ត្រមួយចំនួនដែលត្រូវអនុវត្តន៍ គឺពង្រឹងការវាយតំលៃអតិថិជនរបស់ខ្លួនឱ្យបានត្រឹមត្រូវ ជៀសវាងផ្តល់ទុនត្រួតគ្នា និងការសងត្រឡប់វិញរបស់អតិថិជនបានទាន់ពេល និងគ្រប់ចំនួន។

ការកសាងអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ ពិតជាមានការលំបាកខ្លាំង ប្រទេសកម្ពុជាយើងបានទទួលជោគជ័យដូចបច្ចុប្បន្ននេះ គឺពិតជាកើតចេញពីការប្រឹងប្រែងរួមគ្នា របស់ប្រជាពលរដ្ឋ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ភ្នាក់ងារហិរញ្ញវត្ថុអន្តរជាតិ និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ដែលតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា នាំមកនូវបច្ចេកវិទ្យាថ្មីនេះ ឆ្លើយតបនឹងតំរូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងនាមជាប្រជាពលរដ្ឋខ្មែរម្នាក់ ជាប្រជាជាតិដែលមានអរិយធម៌ វប្បធម៌រុងរឿង យើងគួរមានឯកសិទ្ធិឈរស្មើនឹងប្រជាជាតិនានាលើសកលលោក។ ការនាំគ្នាគេចពីបំណុល គឺជាការនាំគ្នាស្វែងរកឱកាសក្លាយខ្លួនជាមនុស្សខ្សោយគ្មានការជឿជាក់ទុកចិត្តដែលបាត់បង់ឱកាសអភិវឌ្ឍរបស់ខ្លួន។ ផ្ទុយមកវិញ កាយវិការទទួលខុសត្រូវលើបំណុលរបស់យើង ពិតជាការចាប់ផ្តើមបង្ហាញពីភាពរឹងមាំរបស់ប្រជាជាតិមួយលើសកលលោក ហើយយើងអាចទទួលបានវិញនូវការជឿជាក់ទុកចិត្តពីគ្រប់មជ្ឈដ្ឋានដែលនាំមកការ អភិវឌ្ឍឥតឈប់ឈរ។